# សេផានា Zephaniah

## កាលៈទេសៈតាមប្រវត្តិសាស្ត្រនៅសម័យសេផានានិងខ្លឹមសារនៃប្រសាសន៍របស់សេផានា Historical background to Zephaniah and basic message

ស្តេចម៉ាន៉ាសេបានដឹកនាំប្រជាជនយូដាអោយថ្វាយបង្គំព្រះបាលនិងអនុវត្តពិធីសាសនាផ្សេងៗ ដែលព្រះស្អប់ខ្ពើម (ចោទិយកថា ១៨:៩-១២)។ ស្តេចម៉ាន៉ាសេបាននាំយករូបព្រះមកក្នុងព្រះវិហារ ហើយថែមទាំងថ្វាយបុត្រារបស់ខ្លួនផ្ទាល់ជាយញ្ញបូជានៅលើអាសនារបស់ព្រះដទៃទៀតផង។ ទោះបីជានៅចុងក្រោយស្តេចម៉ាន៉ាសេប្រែចិត្តពីទង្វើរបស់ខ្លួន ក៏បុត្រារបស់ទ្រង់ ឈ្មោះអាំម៉ូន គឺជាអ្នកថ្វាយបង្គំរូបព្រះទៅហើយ (២របាក្សាត្រ ៣៣)។ ប្រជាជនយូដានាំគ្នាតែងតាំងយ៉ូសៀសជាបុត្រអាំម៉ូនអោយឡើងស្នងរាជ្យជំនួសអាំម៉ូន (២ពង្សាវតារក្សត្រ ២១:២៤)។

ហោរាសេផានាបានប្រកាសព្រះបន្ទូលនៅក្នុងកំឡុងរាជ្យរបស់ស្តេចយ៉ូសៀស (៦៤០-៦០៩ មុនគ.ស.)។ យើងគួរតែចាប់អារម្មណ៍ចំពោះហោរាសេផានា ពីព្រោះព័ន្ធកិច្ចរបស់គាត់បានចាប់ផ្តើមក្នុងពេលដែលស្តេចយ៉ូសៀសកំពុងកំណែទម្រង់សាសនារបស់យូដា។ ២ពង្សាវតារក្សត្រ ២២-២៣ ពិពណ៌នាអំពីកំណែទម្រង់ទាំងនេះ ដែលបានចាប់ផ្តើមឡើងដោយព្រោះពួកគេបានរកឃើញ «គម្ពីរក្រិត្យវិន័យ» នៅក្នុងព្រះវិហារ។ ដូច្នេះ គួរអោយភ្ញាក់ផ្អើល ដែលការប្រកាសព្រះបន្ទូលរបស់សេផានា ដែលរិះគន់ដល់យូដាយ៉ាងខ្លាំង បានចាប់ផ្តើមក្នុងកំឡុងរាជ្យរបស់ស្តេចស្មោះត្រង់និងសុចរិតមួយអង្គ។ កំណែទម្រង់មិនអាចធ្វើអោយមានការផ្លាស់ប្រែដ៏ជ្រាលជ្រៅនៅក្នុងប្រជាជន ដែលព្រះសព្វព្រះទ័យចង់បាននោះទេ។ ប្រជាជនត្រូវការការផ្លាស់ប្រែចិត្តទាំងស្រុង (៤:៤)។

ស្ទើរតែដូចជាពួកហោរាទាំងអស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហោរាសេផានាបានថ្លែងនូវចំនុចចំបងបីនៅក្នុងសាររបស់គាត់គឺៈ

១. រាស្ត្ររបស់ព្រះ (ក្នុងករណីនេះជាអស់អ្នកនៅក្នុងយូដា) បានបះបោរប្រឆាំងនឹងព្រះ។

២. ដោយសារការបះបោររបស់រាស្ត្ររបស់ទ្រង់ នោះព្រះអម្ចាស់នឹងវិនិច្ឆ័យពួកគេ ហើយទ្រង់នឹងវិនិច្ឆ័យមនុស្សលោកទាំងមូលផងដែរ។

៣. ប៉ុន្តែ ព្រះស្មោះត្រង់និងមានសេចក្តីមេត្តាករុណា ហើយទ្រង់នឹងស្តារនិងសង្គ្រោះរាស្ត្ររបស់ទ្រង់។

## គម្រោង Outline

១. ចំណងជើង (១:១)
២. ការវិនិច្ឆ័យនឹងធ្លាក់មកលើយូដា (១:២-៦)
៣. ថ្ងៃនៃព្រះអម្ចាស់ (១:៧-៣:២០)
ក. ថ្ងៃនៃយញ្ញបូជានិងទណ្ឌកម្ម (១:៧-៩)
ខ. សេចក្តីក្រោធដែលនឹងមកដល់ (១:១០-១៨)
គ. ចូរប្រែចិត្ត (២:១-៣)
ឃ. ជាតិសាសន៍ទាំងអស់ត្រូវបានព្រមាន (២:៤-៣:៨)
ង. សេចក្តីសង្ឃឹមនាពេលអនាគត (៣:៩-២០)

## របៀបអានកណ្ឌសេផានា How to read Zephaniah

ដើម្បីយល់និងអនុវត្តកណ្ឌសេផានាអោយបានត្រឹមត្រូវ សំខាន់យើងត្រូវយល់កណ្ឌនេះនៅក្នុងបរិបទដើមរបស់វានៅក្នុងប្រវត្តិសាស្ត្រ និងនៅក្នុងបរិបទនៃព្រះគម្ពីរទាំងមូល។ ដើម្បីយល់បែបនេះបាន យើងត្រូវឆ្លើយនឹងសំនួរប្រាំមួយដូចខាងក្រោម។

១. តើកណ្ឌសេផានាទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?

២. តើគោលបំណងរបស់កណ្ឌសេផានាសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

៣. តើកណ្ឌសេផានាទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?

៤. តើកណ្ឌនេះបង្រៀនយើងអ្វីអំពីព្រះ?

៥. តើកណ្ឌនេះបង្រៀនយើងអ្វីអំពីមនុស្ស?

៦. តើកណ្ឌនេះអនុវត្តមកកាន់គ្រីស្ទបរិស័ទសព្វថ្ងៃយ៉ាងដូចម្តេច?

### ១. តើកណ្ឌសេផានាទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?

ព្រះគម្ពីរគឺជារឿងធំមួយ ដែលពន្យល់អំពីផែនការរបស់ព្រះចាប់តាំងពីការបង្កបង្កើតដល់ការបង្កបង្កើតថ្មី។ ទ្រង់បានបង្កើតគ្រប់យ៉ាងល្អជាដំបូង ដោយមានអ័ដាម និងអេវ៉ានៅក្នុងសួនច្បារអេដែន។ ពួកគេគឺជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រង និងព្រះពររបស់ព្រះ។ នេះគឺជាគោលដៅរបស់ព្រះសំរាប់ការបង្កបង្កើត។ ពួកគេមិនបានស្តាប់បង្គាប់ ហើយត្រូវបានបណ្តេញចេញពីសួនច្បារ ដែលជាទីបរិសុទ្ធរបស់ព្រះ។ កន្លែងផ្សេងៗទាំងអស់ទៀតក្នុងព្រះគម្ពីរនិយាយអំពីផែនការរបស់ព្រះ ក្នុងការសង្គ្រោះមនុស្សចេញពីលទ្ធផលនៃការបះបោរនេះ ហើយស្តារនគររបស់ទ្រង់ឡើងវិញ ដែលជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការ

គ្រប់គ្រងនិងព្រះពររបស់ព្រះ។ ដូច្នេះ ព្រះបានជ្រើសរើសអ័ប្រាហាំ ហើយបានសន្យាថា ទ្រង់នឹងធ្វើអោយគាត់ក្លាយជាជាតិសាសន៍មួយដ៏ធំ ហើយពួកគេនឹងទទួលបានទឹកដីសន្យា។ តាមរយៈពូជពង្សរបស់អ័ប្រាហាំ ព្រះនឹងប្រទានពរដល់លោកិយ (លោកុប្បត្តិ ១២:៣)។ ពួកគេត្រូវតែជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ ទ្រង់នឹងគង់ក្នុងចំណោមពួកគេ ដូច្នេះអ៊ីស្រាអែលនៅក្នុងទឹកដីសន្យាគឺអេដែនថ្មី ដែលជាទីបរិសុទ្ធថ្មី (សូមមើល លោកុប្បត្តិ ១៣:១០)។ ព្រះបានមានបន្ទូលនៅក្នុងនិក្ខមនំ ១៩:៤-៦ ថា ទ្រង់បានជ្រើសរើសអ៊ីស្រាអែលធ្វើជារាស្ត្រពិសេសរបស់ទ្រង់ ហើយក្នុងចោទិយកថា ៤ ចែងថា ពួកគេត្រូវធ្វើជាពន្លឺដល់ជាតិសាសន៍ដទៃទាំងអស់។ ចោទិយកថា ២៨ ប្រកាសបណ្តាសាររបស់សម្ព័ន្ធមេត្រីថា បើសិនអ៊ីស្រាអែលមិនស្មោះត្រង់ចំពោះព្រះ និងធ្វើតាមការត្រាស់ហៅរបស់ខ្លួនទេ នោះព្រះនឹងបញ្ជូនពួកគេចេញពីទឹកដី។ បន្ទាប់ពីស្តេចសាឡូម៉ូនមក នគរត្រូវបែងចែកជាពីរផ្នែក គឺនគរខាងជើងហៅថា អ៊ីស្រាអែល ហើយនគរខាងត្បូងហៅថា យូដា ដែលមានយេរូសាឡិមជារាជធានី។ ការផ្តាច់សម្ព័ន្ធមេត្រីនិងការថ្វាយបង្គំរូបព្រះនាំទៅដល់ពេលវេលា ដែលអ៊ីស្រាអែលធ្លាក់ចុះ។ ទោះបីជាមានស្តេចមួយចំនួនដូចជា ស្តេចហេសេគា និងយ៉ូសៀស ប៉ុនប៉ងកំណែទម្រង់ក៏ដោយ ក៏ដំណើរការនៃការធ្លាក់ចុះមិនអាចត្រឡប់ថយក្រោយបានឡើយ ហើយពួកគេត្រូវបញ្ចប់ដោយការវិនាសនៃសញ្ញាដែលមើលឃើញទាំងអស់នៃសម្ព័ន្ធមេត្រីរបស់អ៊ីស្រាអែលជាមួយនឹងព្រះ ដូចជា យេរូសាឡិម និងព្រះវិហារ។

ចំនុចទាំងនេះមានសារៈសំខាន់ណាស់ ដើម្បីយល់កណ្ឌសេផានា។ ហោរាសេផានាបានប្រកាសថា អ៊ីស្រាអែលមិនបានធ្វើតាមការត្រាស់ហៅរបស់ខ្លួន ក្នុងការធ្វើជាជាតិសាសន៍បរិសុទ្ធ និងជាពន្លឺដល់ជាតិសាសន៍ដទៃទាំងអស់ទេ ហើយព្រះពិតជានឹងដាក់ការជំនុំជំរះលើពួកគេ តាមការព្រមាននៅក្នុងចោទិយកថាជំពូក២៨។ ដូច្នេះ ការជំនុំជំរះ ដែលព្រះបានប្រកាសតាមរយៈហោរាសេផានា ត្រូវបានព្រមានរួចហើយនៅក្នុងកណ្ឌចោទិយកថា។ ការព្រមានពីសម័យមុនទាំងនេះគឺជាមូលដ្ឋានគ្រឹះនៃការប្រកាសរបស់ហោរាសេផានា។

## ២. តើគោលបំណងរបស់កណ្ឌសេផានាសម្រាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

ជាដំបូង ហោរាសេផានាបានព្រមានយូដាថា បើសិនពួកគេមិនប្រែចិត្តទេ នោះពួកគេនឹងប្រឈមនឹងការវិនិច្ឆ័យ បន្ទាប់មក គាត់បានប្រកាសថា ការវិនិច្ឆ័យរបស់ព្រះនឹងមកជាពិត។ ខ្លាដែលពិពណ៌នាអំពីការជំនុំជំរះនេះគឺ «ថ្ងៃដ៏ឧត្តុង្គឧត្តមរបស់ព្រះអម្ចាស់» (និង «ថ្ងៃនោះ» ដែលសំដៅទៅលើថ្ងៃរបស់ព្រះអម្ចាស់ (១:៧-១០, ១៤-១៨; ២:២-៣; ៣:៥, ៨, ១១, ១៦)។ គាត់ក៏បានប្រាប់ផងដែរថា អនាគតគេនឹងពោរពេញដោយសេចក្តីសង្ឃឹម ពីព្រោះព្រះយេហូវ៉ាជាព្រះរបស់គេ ទ្រង់គង់ជាមួយគេហើយនឹងសង្គ្រោះពួកគេ (៣:១៧)។

## ៣. តើកណ្ឌសេផានាទាក់ទងនឹងកណ្ឌផ្សេងៗទៀត ដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?

មានរបៀបជាច្រើន ដែលកណ្ឌសេផានាទាក់ទំនងនឹងកណ្ឌផ្សេងៗ ដែលមានបន្ទាប់ពីវា។ នៅពេលពួកហោរាទាយអំពីការស្តារអ៊ីស្រាអែលនិងយូដាឡើងវិញ នៅក្នុងរបៀបផ្សេងៗ ពួកហោរា ដែលសរសេរកណ្ឌគម្ពីរបានប្រកាសអំពីសេចក្តីសង្ឃឹមអំពីអ្វីដែលព្រះនឹងធ្វើនៅក្នុងអនាគត ដោយប្រើរូបភាពចេញពីអ្វីដែលទ្រង់បានធ្វើនៅក្នុងអតីតកាល។ ការបង្កើតជាថ្មីគឺជាព្រឹត្តិការណ៍នៅក្នុងពេលអនាគត ដែលហោរាមួយចំនួននិយាយថា នឹងកើតឡើងនៅ «ថ្ងៃនៃព្រះអម្ចាស់»។ ពួកហោរាមើលឃើញថា សេចក្តីសង្គ្រោះនាពេលអនាគតខុសគ្នានឹងការស្តារឡើងវិញនៅអតីតកាល ពីព្រោះការបង្កើតជាថ្មី ដែលនឹងមកដល់នេះ មានភាពឥតខ្ចោះ ពេញដោយសិរីល្អ ហើយនិងស្ថិតស្ថេរអស់កល្បជានិច្ច។

ពិតណាស់ថា ការបង្កើតជាថ្មីនៅពេលចុងក្រោយនេះមិនបានកើតឡើងនៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ទេ។ ការស្តារឡើងវិញនេះបានមកដល់ នៅពេលព្រះយេស៊ូវបានយាងមកក្នុងស្រុកកាលីឡេ ហើយប្រកាសដំណឹងល្អ ដោយមានបន្ទូលថា «ពេលវេលាបានសំរេចហើយ នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្តហើយជឿដំណឹងល្អចុះ» (ម៉ាកុស ១:១៤-១៥)។ ព្រះគម្ពីរសញ្ញាថ្មីចាប់យកផ្ទៃរឿងដ៏អស្ចារ្យផ្សេងៗនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយយល់ថា ផ្ទៃរឿងទាំងនោះត្រូវបានបំពេញសំរេចនៅក្នុងព្រះយេស៊ូវ។

ផ្ទៃរឿងមួយទៀត ដែលទាក់ទងនឹងអ្វី ដែលមកតាមក្រោយនៅក្នុងព្រះគម្ពីរសញ្ញាចាស់និងសញ្ញាថ្មីគឺ «សំណល់សល់» (៣:១៣) ។ ទីមួយ អស់អ្នកណា ដែលជាអ្នកជ្រើសរើសរបស់ព្រះចេញពីក្នុងចំណោមអ៊ីស្រាអែលក្នុងកំឡុងនិងបន្ទាប់ពីការនិរទេស ត្រូវបានហៅថា «សំណល់សល់» របស់ទ្រង់។ ព្រះគម្ពីរសញ្ញាថ្មីបង្រៀនថា «សំណល់សល់» គឺជាអស់អ្នកណា ដែលនៅក្នុងព្រះគ្រីស្ទ ទោះជាសាសន៍យូដា ឬពួកសាសន៍ដទៃ (រ៉ូម ១១:៥)។

## ៤. តើកណ្ឌសេផានាបង្រៀនយើងអ្វីខ្លះអំពីព្រះ?

តាមការរៀបរាប់ខាងលើនេះ យើងមើលឃើញថា កណ្ឌសេផានាបង្រៀនថា

- ទ្រង់បរិសុទ្ធ និងទតឃើញគ្រប់ទាំងអស់ ហើយដាក់ទណ្ឌកម្មចំពោះអំពើបាប។
- ព្រះស្អប់ការថ្វាយបង្គំរូបព្រះនិងព្រះក្លែងក្លាយ (១:៤-៥,៩; ២:១១)។
- ព្រះព្រមានរាស្ត្ររបស់ព្រះ។
- ព្រះអង្គគ្រប់គ្រងប្រវត្តិសាស្ត្ររបស់មនុស្សជាតិដោយព្រះបន្ទូលរបស់ទ្រង់។ តាមប្រវត្តិសាស្ត្រព្រះបានបំពេញសំរេចការព្រមាន ដែលទ្រង់បានប្រកាសតាមរយៈហោរាសេផានា។
- ទ្រង់មានបន្ទូលមកកាន់រាស្ត្ររបស់ទ្រង់ ហើយពន្យល់អំពីផែនការរបស់ទ្រង់សំរាប់លោកិយ។

- ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះបានបញ្ជូនពួកហោរារបស់ទ្រង់មកឯរាស្ត្ររបស់ទ្រង់ ដើម្បីប្រាប់ពួកគេអោយប្រែចិត្ត។ ដូចគ្នាផងដែរ សព្វថ្ងៃនេះ ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះបញ្ជូនគ្រីស្ទបរិស័ទទៅក្នុងលោកិយ ដើម្បីប្រកាសដំណឹងល្អអោយមនុស្សបានជឿលើព្រះយេស៊ូវ និងងាកបែរមករកទ្រង់វិញ។
- ព្រះទ្រង់ប្រច័ណ្ឌ (១:១៨)។
- ព្រះអង្គសព្វព្រះហឫទ័យនឹងសេចក្តីយុត្តិធម៌ (៣:១-៥)។
- ទ្រង់ជំនុំជំរះរាស្ត្ររបស់ព្រះ (៣:៩)។
- ព្រះជាម្ចាស់ប្រឆាំងនឹងមនុស្សមានអំនួត (៣:១១-១២)។
- ព្រះទ្រង់សង្គ្រោះរាស្ត្ររបស់ទ្រង់ ហើយព្រះអង្គមានអំណរសប្បាយជាខ្លាំងព្រោះតែរាស្ត្ររបស់ព្រះ (៣:១៧)។
- ទ្រង់គង់នៅជាមួយរាស្ត្ររបស់ទ្រង់ (៣:១៧)។
- ទ្រង់ធ្វើអោយរាស្ត្ររបស់ព្រះមានកេរ្តិ៍ឈ្មោះល្បី និងមានកិត្តិយសក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មាននៅលើផែនដី។

## ៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

- មនុស្សបះបោរប្រឆាំងនឹងព្រះ ហើយសមនឹងទទួលទណ្ឌកម្មពីទ្រង់។
- មនុស្សចូលចិត្តថ្វាយបង្គំរូបព្រះនិងព្រះក្លែងក្លាយ។
- នៅពេលមនុស្សភ្លេចព្រះហើយតាមរូបព្រះ នោះសីលធម៌របស់ពួកគេធ្លាក់ចុះ។

## ៦. តើកណ្ឌនេះអនុវត្តមកកាន់គ្រីស្ទបរិស័ទសព្វថ្ងៃយ៉ាងដូចម្តេច?

កណ្ឌអេសាយទាក់ទងនឹងជីវិតរបស់យើងនៅសព្វថ្ងៃនេះនៅក្នុងរបៀបជាច្រើន។

១. ជាដំបូង យើងត្រូវតែមើលឃើញថាកណ្ឌសេផានាទាក់ទងនឹងជីវិតរបស់យើងតាមរយៈព្រះយេស៊ូវ។ គ្រប់ទំនាយនិងសេចក្តីសន្យាទាំងអស់អំពីព្រះយេស៊ូវ ដែលបានលើកឡើងនៅចំណុចជើងទី៣ខាងលើ បង្ហាញអំពីរបៀបដែលកណ្ឌសេផានាមានការអនុវត្តចំពោះយើង។

២. ប៉ុន្តែសេចក្តីសន្យាអំពីការវិនិច្ឆ័យបានរៀបចំយើងសំរាប់ព្រះបន្ទូលអំពីព្រះគុណ (៣:៩-២០) ដែលហោរាសេផានាដាស់តឿនយូដាអោយច្រៀង ពីព្រោះព្រះបានដកយកការវិនិច្ឆ័យរបស់យូដាចេញហើយ។ សំរាប់យើងនៅសព្វថ្ងៃនេះ យើងទទួលបានសេចក្តីអត់ទោសនេះតាមរយៈព្រះយេស៊ូវយ៉ាងជាក់ច្បាស់។

៣. យើងបានមើលឃើញថា ផ្ទៃរឿងចំបងមួយនៅក្នុងកណ្ឌសេផានាគឺ ថ្ងៃនៃព្រះអម្ចាស់។ ថ្ងៃនៃព្រះអម្ចាស់ក្លាយជាថ្ងៃនៃព្រះយេស៊ូវគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាថ្មី (រ៉ូម ២:១៦; ១កូរិនថូស ១:៨; ភីលីព ១:៦,១០; ២:១៦) ជាថ្ងៃដែលព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញ ដើម្បីវិនិច្ឆ័យលោកិយទាំងមូល។ អស់អ្នកណា ដែលទុកចិត្តលើទ្រង់ ត្រូវបានអត់ទោសអោយរួចហើយ តាមរយៈព្រះយេស៊ូវបានទទួលយកទណ្ឌកម្មរបស់យើងនៅលើឈើឆ្កាង។

៤. ការដាស់តឿនរបស់ហោរាសេផានាចំពោះយូដាក៏ទាក់ទងនឹងយើងនៅសព្វថ្ងៃនេះផងដែរ។ គាត់ដាស់តឿនយើងអោយប្រែចិត្តចេញពីអំពើបាបនិងការថ្វាយបង្គំរូបព្រះរបស់យើង ពីព្រោះព្រះទ្រង់បរិសុទ្ធនិងមានសេចក្តីប្រច័ណ្ឌ។ ហើយយើងក៏មានអំណរ ដោយបង្ហូរការសរសើរតម្កើងរបស់យើងចំពោះទ្រង់ផងដែរ ពីព្រោះព្រះដែលវិនិច្ឆ័យ ទ្រង់ក៏នឹងប្រោសលោះយើងតាមរយៈព្រះយេស៊ូវផងដែរ។

៥. ហោរាសេផានាបង្ហាញត្រួសៗថា ពួកអ្នកដឹកនាំត្រូវទទួលខុសត្រូវនិងមានជីវិតបរិសុទ្ធ ហើយគាត់ព្រមានអំពីអំពើពុករលួយនៅក្នុងរាស្ត្ររបស់ព្រះអាចរាលដាល (៣:៣-៤)។